ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៤០៥៤ អពដ

# សេចក្តីណែនាំ

## ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបគេចបន្ទុកពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

អនុលោមតាមប្រកាសលេខ១១៦ សហវ.ប្រក ចុះថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបគេចបន្ទុកពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល (Double Taxation Agreement-DTA) រវាង÷

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់និងយ៉ាងឌីពើរតួន នៃប្រទេសព្រុយណេដារូសាឡឹម និង
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃ។

ដើម្បីសម្រួលក្នុងការអនុវត្ត អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដូចខាងក្រោម÷

### ១. បុគ្គលដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀង

បុគ្គលដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងគឺនិវាសនជននៃព្រះរាជាណាចក្រកម្ពុជា និងនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

### ២. ប្រភេទពន្ធដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀង

សម្រាប់ព្រះរាជាណាចក្រកម្ពុជា ប្រភេទពន្ធដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀង មានពន្ធលើប្រាក់ចំណូល រួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធអប្បបរមា ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ ពន្ធលើចំណូលមូលធន និងពន្ធលើប្រាក់បៀវត្ស។

### ៣. វិធានក្នុងការកំណត់និវាសនជន

និវាសនជនក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅដល់÷

ក- រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានទីកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃ នៅក្នុងរយៈពេល ១២ខែណាមួយ ដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។

ខ- នីតិបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



អាគារតេជោមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

## ៤. រូបវន្តបុគ្គលជានិវាសនជននៃរដ្ឋភាគីទាំងពីរ

ក្នុងករណី រូបវន្តបុគ្គលជានិវាសនជននៃព្រះរាជាណាចក្រកម្ពុជាផង និងជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងផង÷

ក- រូបវន្តបុគ្គល ត្រូវកំណត់ថាជានិវាសនជនរបស់រដ្ឋភាគីណាមួយ ដែលរូបវន្តបុគ្គលនោះមានទីលំនៅអចិន្ត្រៃយ៍។ ប្រសិនបើរូបវន្តបុគ្គលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីទាំងពីរ រូបវន្តបុគ្គលនោះត្រូវចាត់ទុកថាជានិវាសនជនតែក្នុងរដ្ឋភាគីណាមួយ ដែលមានទំនាក់ទំនងផ្ទាល់ខ្លួននិងទំនាក់ទំនងសេដ្ឋកិច្ចជិតស្និទ្ធជាង (មូលដ្ឋានផលប្រយោជន៍សំខាន់)។

ខ- ប្រសិនបើពុំអាចកំណត់បាននូវរដ្ឋភាគីដែលរូបវន្តបុគ្គលមានមូលដ្ឋានផលប្រយោជន៍សំខាន់ៗ ឬរូបវន្តបុគ្គលគ្មានទីលំនៅអចិន្ត្រៃយ៍ក្នុងរដ្ឋភាគីណាមួយ រូបវន្តបុគ្គលត្រូវបានចាត់ទុកថាជានិវាសនជនតែក្នុងរដ្ឋភាគីដែលបុគ្គលនោះ មានកន្លែងស្នាក់នៅជាទម្លាប់។

គ- ប្រសិនបើរូបវន្តបុគ្គលមាន ឬគ្មានកន្លែងស្នាក់នៅជាទម្លាប់នៅក្នុងរដ្ឋភាគីទាំងពីរ រូបវន្តបុគ្គលត្រូវចាត់ទុកថាជានិវាសនជនតែក្នុងរដ្ឋភាគី ដែលរូបវន្តបុគ្គលនោះ មានសញ្ជាតិ។

ឃ- ប្រសិនបើរូបវន្តបុគ្គលមានសញ្ជាតិនៅក្នុងរដ្ឋភាគីទាំងពីរ ឬគ្មានសញ្ជាតិក្នុងរដ្ឋភាគីណាមួយ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ត្រូវកំណត់ភាពជានិវាសនជនរបស់រូបវន្តបុគ្គលនោះ តាមរយៈការព្រមព្រៀងទៅវិញទៅមក។

## ៥. នីតិបុគ្គលជានិវាសនជននៃរដ្ឋភាគីទាំងពីរ

ក្នុងករណី នីតិបុគ្គលណាមួយជានិវាសនជននៃព្រះរាជាណាចក្រកម្ពុជាផង និងជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងផង នីតិបុគ្គលនោះ ត្រូវបានកំណត់ថាជានិវាសនជននៃរដ្ឋភាគីណាមួយ ស្របតាមលក្ខខណ្ឌកំណត់ក្នុងកិច្ចព្រមព្រៀង ជាអាទិ៍មាន ទីកន្លែងចុះបញ្ជីនីតិបុគ្គល ឬតាមរយៈនីតិវិធីព្រមព្រៀងទៅវិញទៅមក។

## ៦. វិញ្ញាបនបត្រនិវាសនជន

ដើម្បីទទួលបានវិញ្ញាបនបត្រនិវាសនជន បុគ្គលនិវាសនជននៃព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ តាមទម្រង់ដែលបានកំណត់ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា ដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃសេចក្តីណែនាំនេះ។ ចំពោះបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ រួមទាំងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម។

វិញ្ញាបនបត្រនិវាសនជនមានសុពលភាពរយៈពេល ០១ ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។

## ៧. អត្រាពន្ធកាត់ទុកក្រោមកិច្ចព្រមព្រៀង

អត្រាពន្ធកាត់ទុកលើភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវាបច្ចេកទេស ដែលបង់ទៅឱ្យបុគ្គលនិវាសនជននៃរដ្ឋភាគីម្ខាងទៀត ត្រូវអនុវត្តតាមមាត្រា ២៦ ថ្មី (មួយ)នៃច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមិនឱ្យលើសពីអត្រាកំណត់នៅក្នុងកិច្ចព្រមព្រៀង។

ដើម្បីទទួលបានអត្រាពន្ធកាត់ទុក ដែលកំណត់ក្នុងកិច្ចព្រមព្រៀង អ្នកជាប់ពន្ធត្រូវ÷

ក- មានឯកសារបញ្ជាក់និវាសនជនពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង និង

ខ- ជាម្ចាស់សិទ្ធិអាស្រ័យផល (Beneficial Owner)។

អ្នកជាប់ពន្ធ ត្រូវដាក់ពាក្យស្នើសុំមកនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ តាមទម្រង់ដែលបានកំណត់ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា ដូចមានចែងក្នុងឧបសម្ព័ន្ធ២ នៃសេចក្ដីណែនាំនេះ។

## ៨. ការលើកលែងពន្ធកាត់ទុកលើការប្រាក់

ការប្រាក់ដែលមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបានទូទាត់ទៅឱ្យរដ្ឋាភិបាលនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ត្រូវបានលើកលែងពន្ធកាត់ទុកតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង។ អ្នកជាប់ពន្ធត្រូវដាក់ពាក្យស្នើសុំមកនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ តាមទម្រង់ដែលបានកំណត់ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា ដូចមានចែងក្នុងឧបសម្ព័ន្ធ២ នៃសេចក្ដីណែនាំនេះ។

## ៩. ចំណូលពីប្រតិបត្តិការតាមយន្តហោះក្នុងចរាចរណ៍អន្តរជាតិ

ប្រាក់ចំណូល ដែលបានមកពីប្រតិបត្តិការយន្តហោះក្នុងចរាចរណ៍អន្តរជាតិរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ត្រូវជាប់ពន្ធលើប្រាក់ចំណូលតែក្នុងប្រទេសនិវាសនដ្ឋានប៉ុណ្ណោះ។

សហគ្រាសដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ត្រូវមានលិខិតបញ្ជាក់និវាសនជនពីអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន។

សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ត្រូវដាក់ពាក្យស្នើសុំមកនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ តាមទម្រង់ដែលបានកំណត់ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា ដូចមានចែងក្នុងឧបសម្ព័ន្ធ២ នៃសេចក្ដីណែនាំនេះ។

## ១០. ចំណូលពីប្រតិបត្តិការនៃនាវាឬទូក ឬតាមផ្លូវដែកឬផ្លូវគោក ក្នុងចរាចរណ៍អន្តរជាតិ

ប្រាក់ចំណូលដែលបានមកពីប្រតិបត្តិការនាវាឬទូក ឬមធ្យោបាយដឹកជញ្ជូនតាមផ្លូវដែកឬផ្លូវគោកក្នុងចរាចរណ៍អន្តរជាតិរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង អាចជាប់ពន្ធលើប្រាក់ចំណូលក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ប៉ុន្តែប្រាក់ពន្ធដែលបានកំណត់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ ត្រូវកាត់បន្ថយ ៥០ភាគរយ។

សហគ្រាសដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ត្រូវមានលិខិតបញ្ជាក់និវាសនជនពីអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន។

សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ត្រូវដាក់ពាក្យស្នើសុំមកនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ តាមទម្រង់ដែលបានកំណត់ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា ដូចមានចែងក្នុងឧបសម្ព័ន្ធ២ នៃសេចក្ដីណែនាំនេះ។

## ១១. វិធានសម្រាប់ការលុបបំបាត់ការយកពន្ធត្រួតគ្នា

ក្នុងករណីដែលអ្នកជាប់ពន្ធមានប្រាក់ចំណូល ដែលត្រូវជាប់ពន្ធក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ អ្នកជាប់ពន្ធដែលជានិវាសនជននៃរដ្ឋភាគីម្ខាង មានសិទ្ធិទទួលបានឥណទានពន្ធចំពោះប្រាក់ពន្ធដែលបានបង់នៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ដើម្បីកាត់កងចេញពីប្រាក់ពន្ធដែលត្រូវបង់នៅប្រទេសនិវាសនដ្ឋានរបស់ខ្លួន។ ដើម្បីទទួលបាននូវឥណទានពន្ធ អ្នកជាប់ពន្ធត្រូវមានលិខិតបញ្ជាក់ការបង់ពន្ធដែលបានបង់នៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ។

ឧទាហរណ៍÷ និវាសនជននៃកម្ពុជាដែលមានប្រភពចំណូលមកពីប្រទេសថៃ ហើយបានបង់ពន្ធលើប្រាក់ចំណូលនេះ តាមច្បាប់ពន្ធរបស់ថៃរួចរាល់ អាចទទួលបានឥណទានពន្ធនៅកម្ពុជា។ ដើម្បីទទួលបាននូវឥណទានពន្ធនេះ និវាសនជនកម្ពុជាត្រូវមានលិខិតបញ្ជាក់ត្រឹមត្រូវពីការបង់ពន្ធ ដែលចេញដោយអាជ្ញាធរពន្ធដារថៃ។

## ១២. ការដោះស្រាយវិវាទ

ការដោះស្រាយវិវាទដែលកើតឡើងក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

អ្នកជាប់ពន្ធមានសិទ្ធិដាក់ពាក្យប្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងរបស់ខ្លួនក្នុងករណីមិនពេញចិត្តនឹងដំណោះស្រាយតាមច្បាប់ក្នុងស្រុក។ ការដាក់ពាក្យប្តឹងតវ៉ាត្រូវធ្វើឡើងក្នុងរយៈពេល ០៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

ការដោះស្រាយបណ្តឹងតវ៉ាតាមរយៈអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ត្រូវផ្អែកលើគោលការណ៍នៃនីតិវិធីនៃការព្រមព្រៀងទៅវិញទៅមក ដូចមានចែងក្នុងកិច្ចព្រមព្រៀងនីមួយៗ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់ថា អ្នកជាប់ពន្ធនិវាសនជននៃព្រះរាជាណាចក្រកម្ពុជា និងនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ស្ថាប័នរដ្ឋ និងអង្គការនានាដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងនេះ នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារ នៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ច័ន្ទ ១០កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ